ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងរដ្ឋប្បវេណីលេខ៨១៤
ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២
សាលក្រមលេខ:០២៥/២២-ធ-
ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២

# ក្នុងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកណ្ដាល

បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២២ និងប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ លើសំណុំរឿងរដ្ឋប្បវេណីលេខ:៨១៤ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២។

**ដោយមានសមាសភាព**

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

**រវាងដើមចោទ:**

ឈ្មោះ [redacted] មករា ភេទស្រី កើតឆ្នាំ១៩៨៣ សញ្ជាតិខ្មែរ មុខរបរធ្វើការរោងចក្រ មានអាសយដ្ឋាន ផ្ទះលេខ [redacted]។

ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ។

**និងចុងចម្លើយ:**

ឈ្មោះ [redacted] ស៊ីនឿន ភេទប្រុស កើតឆ្នាំ១៩៧៥ សញ្ជាតិខ្មែរ មុខរបរបើកបរ មានអាសយដ្ឋាន ផ្ទះលេខ [redacted]។

## អង្គហេតុ និងការអះអាងរបស់គូភាគី

### ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ៖

១. ប្ដឹងសុំលែងលះពីប្ដីឈ្មោះ [redacted] ស៊ីនឿន។

២.សុំសិទ្ធិអំណាចមេបាលើកូនទាំង០៣នាក់( កូនទី០១ឈ្មោះ [redacted] ស៊ីយូ ភេទស្រី កើតឆ្នាំ២០០៨ កូនទី០២ ឈ្មោះ [redacted] សុខសៀវម៉ី ភេទស្រី កើតឆ្នាំ២០១១ និងកូនស្រីទី០៣ ឈ្មោះ [redacted] សុនម៉ីនីត កើតឆ្នាំ២០១៤)។

៣.អាហារកាតព្វកិច្ចសម្រាប់ចិញ្ចឹមកូនស្រីទាំង០៣នាក់ ក្នុងមួយ១ខែ៤០ម៉ឺនរៀល។

### ខ. អង្គហេតុ និង ចំណុចវិវាទ

ក្នុងរឿងក្ដីនេះដើមចោទបានថ្លែងការណ៍ថា:ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយប្ដីឈ្មោះ [redacted] ស៊ីនឿន តាមប្រពៃណីខ្មែរ កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៥ ហើយបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍នៅចំពោះមន្ត្រីអាត្រានុកូលដ្ឋានឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្ដាល ដោយមានសំបុត្រអាពាហ៍ពិពាហ៍លេខ:៤៩ ចុះនៃសៀវភៅអាពាហ៍ពិពាហ៍លេខ:០២/២០០៩ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩។ កាលរស់នៅជាមួយគ្នាមានកូនស្រីចំនួនបីនាក់ក្នុងកូនទី០១ ឈ្មោះ [redacted] ស៊ីយូ ភេទស្រី កើតថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨, កូនទី០២ឈ្មោះ [redacted] សុនសៀវម៉ី ភេទស្រី កើតថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១១ និងកូនទី០៣ឈ្មោះ [redacted] សុនម៉ីនីត ភេទស្រី កើត



Scanned with CamScanner

ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៤ ចំណែកទ្រព្យសម្បត្តិរួមពុំមាន និងបំណុលជំពាក់គេក៏គ្មានដែរ។មូលហេតុដែលខ្លួនឈានដល់ការលែងលះគ្នានេះ គឺដោយសារប្តីរបស់ខ្លួនឈ្មោះ [redacted] ស៊ីនឿន ចេះតែរករឿងឈ្លោះប្រកែកជាមួយខ្លួនជាញឹកញាប់ ធ្វើឲ្យកូនៗភ័យខ្លាចរៀនសូត្រមិនចូល មិនតែប៉ុណ្ណោះថែមទាំងទៅប្រព្រឹត្តអំពើអបាយមុខ ដូចជាប្រើប្រាស់ថ្នាំញៀនរហូតដល់មានទោសជាប់ខ្លួន។ ជាហេតុធ្វើឲ្យខ្លួនអស់មនោសញ្ចេតនាមិនអាចនៅរួមរស់ជាមួយគ្នាជាប្តីប្រពន្ធតទៅទៀតឡើយ។ ក្នុងរឿងនេះខ្លួនសំណូមពរសុំលែងលះ ពីប្តីឈ្មោះ [redacted] ស៊ីនឿន, សុំសិទ្ធិគ្រប់គ្រងកូនស្រីទាំងបីនាក់៖ កូនទី០១ ឈ្មោះ [redacted] ស៊ីយូ ភេទស្រី កើតថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ កូនទី០២ឈ្មោះ [redacted] សុនសៀវម៉ី ភេទស្រី កើតថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១១ និងកូនទី០៣ឈ្មោះ [redacted] សុនម៉ីនីត ភេទស្រី កើតថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៤ និងសុំទាមទារអាហារកាតព្វកិច្ចចិញ្ចឹមកូនទាំង៣នាក់ ក្នុងមួយខែ៤០ម៉ឺនរៀល។

ខ.ក.១. រឿងក្តីនេះចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍ថាៈឈ្មោះ [redacted] ស៊ីនឿន បានធ្វើសេចក្តីការណ៍ថា៖ ខ្លួនទទួលស្គាល់កាលរៀបរាប់របស់ដើមចោទ ព្រោះកន្លងមកខ្លួនធ្លាប់ មានទំនាស់ក្នុងគ្រួសារ និងធ្លាប់ប្រើប្រាស់ថ្នាំញៀនពិតប្រាកដមែន ដោយបច្ចុប្បន្នខ្លួនត្រូវតុលាការផ្តន្ទាទោស ឲ្យជាប់ពន្ធនាគាររយៈពេល២ឆ្នាំ ចំពោះការប្តឹងទាមទារ លែងលះរបស់ប្រពន្ធខ្លួនមិនជំទាស់នោះទេ ប៉ុន្តែសុំរង់ចាំពេលខ្លួនចេញពីពន្ធនាគារសិន ពីព្រោះខ្លួននៅជាប់ពន្ធនាគាររយៈតែមួយឆ្នាំប៉ុណ្ណោះ។

**ខ.ខ អង្គហេតុដែលគ្មានវិវាទ**

ដើមចោទឈ្មោះ [redacted] មករា និងចុងចម្លើយឈ្មោះ [redacted] ស៊ីនឿន បានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមប្រពៃណីខ្មែរ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់លេខៈ៤៩ នៃសៀវភៅអាពាហ៍ពិពាហ៍លេខៈ០២/២០០៩ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ នៅចំពោះមន្ត្រីអាត្រានុកូលដ្ឋានឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ពិតប្រាកដមែន។ ការរស់នៅជាប្តី ប្រពន្ធកន្លងមក មានកូនស្រី ចំនួន០៣នាក់ កូនទី០១ ឈ្មោះ [redacted] ស៊ីយូ ភេទស្រី កើតថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨, កូនទី០២ឈ្មោះ [redacted] សុនសៀវម៉ី ភេទស្រី កើតថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១១ និងកូនទី០៣ឈ្មោះ [redacted] សុនម៉ីនីត ភេទស្រី កើតថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៤ ដូចមានបញ្ជាក់នៅក្នុងសំបុត្រកំណើត ដូចភ្ជាប់ជូនមកតុលាការស្រាប់។

-សុំសិទ្ធិអំណាចមេបាលើកូនទាំងបីនាក់ កូនទី០១ ឈ្មោះ សៀ ស៊ីយូ ភេទស្រី កើតថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨, កូនទី០២ឈ្មោះ [redacted] សុនសៀវម៉ី ភេទស្រី កើតថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១១ និងកូនទី០៣ឈ្មោះ [redacted] សុនម៉ីនីត ភេទស្រី កើតថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៤។

-ទ្រព្យសម្បត្តិរួម និងបំណុលរួមគ្មាននោះទេ ។

**ខ.គ ចំណុចវិវាទ**

១.តើដើមចោទឈ្មោះ [redacted] មករា ទាមទារលែងលះពីចុងចម្លើយឈ្មោះ [redacted] ស៊ីនឿន មានមូលហេតុត្រឹមត្រូវតាមច្បាប់ដែរ ឬទេ?

២.តើរវាងដើមចោទឈ្មោះ [redacted] មករា និងចុងចម្លើយឈ្មោះ [redacted] ស៊ីនឿន អ្នកណាស័ក្តិសមធ្វើជាអ្នកមានអំណាចមេបាលើកូនទាំងបីនាក់?

## គ. ការពិនិត្យភស្តុតាង

ឯកសារថតចម្លង សំបុត្រអាពាហ៍ពិពាហ៍លេខ៦០ នៃសៀវភៅអាពាហ៍ពិពាហ៍លេខ០២/២០២១ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២១ របស់មន្ត្រីអាត្រានុកូលដ្ឋានឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល។



Scanned with CamScanner

## សំអាងហេតុ

១. យោងតាមឯកសារថតចម្លង នៃសំបុត្រអាពាហ៍ពិពាហ៍លេខ៤៩ នៃសៀវភៅអាពាហ៍ពិពាហ៍លេខ ០២/២០២២ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ របស់មន្ត្រីអត្រានុកូលដ្ឋានឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្ដាល រវាងដើមចោទឈ្មោះ [redacted] មករា និងចុងចម្លើយឈ្មោះ [redacted] ស៊ីនឿន បានបញ្ជាក់ថាដើមចោទនិងចុងចម្លើយពិតជាសហព័ទ្ធនឹងគ្នាតាមផ្លូវច្បាប់។

២.ផ្អែកតាមពាក្យបណ្ដឹងចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២ និងសេចក្ដីថ្លៃការណ៍របស់ដើមចោទបានបញ្ជាក់ថា ដើមចោទអស់មនោសញ្ចេតនាជាប្ដីប្រពន្ធតទៅទៀតហើយ និងបានសុំឲ្យតុលាការសម្រេចសេចក្ដីលែងលះតាមការស្នើសុំ។ ឃើញថាមូលហេតុលែងលះដែលដើមចោទអះអាង មានភាពត្រឹមត្រូវស្របតាមមាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណី ហេតុដូច្នេះគប្បីតុលាការសម្រេចតាមការស្នើសុំរបស់ដើមចោទ។

៣.ផ្អែកតាមសំបុត្រអាពាហ៍ពិពាហ៍លេខ:៤៩ នៃសៀវភៅអាពាហ៍ពិពាហ៍លេខ:០២/២០០៩ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ សំបុត្រកំណើតរបស់កូនស្រីបីនាក់ក្នុងកូនទី០១ ឈ្មោះ [redacted] ស៊ីយូ ភេទស្រី កើតថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨, កូនទី០២ឈ្មោះ [redacted] សុនសៀវម៉ី ភេទស្រី កើតថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១១ និងកូនទី០៣ឈ្មោះ [redacted] សុនម៉ីនីត ភេទស្រី កើតថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៤។ បញ្ជាក់បានថា ក្នុងចំណងអាពាហ៍ពិពាហ៍រវាងដើមចោទ និងចុងចម្លើយពួកគេទាំងពីរមានកូនស្រីបីនាក់ ដែលមានឈ្មោះ ដូចខាងលើដែលសុទ្ធសឹងតែជាអនីតិជន ហើយដោយពិចារណាលើផលប្រយោជន៍របស់កុមារគប្បីតុលាការកំណត់យកដើមចោទជាអ្នកមានអំណាចមេបាលើកូនទាំងបីនាក់ខាងលើ។

៤. ដើមចោទទាមទារឲ្យចុងចម្លើយជាឪពុកបង់អាហារកាតព្វកិច្ចចាំបាច់ សម្រាប់ចិញ្ចឹមកូនចំនួន៤០ម៉ឺនរៀលក្នុងមួយខែ គប្បីតុលាការពិចារណា លើការទាមទារនេះ ស្របតាមបញ្ញត្តិមាត្រា១១៤០និងមាត្រា១១៤១ នៃក្រមរដ្ឋប្បវេណី ។

៥. ផ្អែកតាមមាត្រា៦៤នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគីចាញ់ក្ដី ។

## សេចក្ដីសម្រេចបញ្ចប់

១.ឱ្យដើមចោទឈ្មោះ [redacted] មករា និងចុងចម្លើយឈ្មោះ [redacted] ស៊ីនឿន លែងលះគ្នា។

២. ឲ្យដើមចោទឈ្មោះ [redacted] មករា ជាអ្នកមានអំណាចមេបាលើកូនស្រីទាំងបីនាក់៖

ក.ឈ្មោះ [redacted] ស៊ីយូ ភេទស្រី កើតថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨។

ខ.ឈ្មោះ [redacted] សុនសៀវម៉ី ភេទស្រី កើតថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១១។

គ.ឈ្មោះ [redacted] សុនម៉ីនីត កើតថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៤។

៣.បង្គាប់ឲ្យភាគីចុងចម្លើយឈ្មោះ [redacted] ស៊ីនឿន បង់អាហារកាតព្វកិច្ចចិញ្ចឹមកូនស្រីទាំងបីនាក់ ក្នុងមួយខែៗចំនួន៣០ម៉ឺនរៀល រហូតដល់កូនមានវ័យនីតិភាព។ ការទាមទារលើសពីនេះត្រូវច្រានចោល។ ចំពោះភាគីដែលពុំមានសិទ្ធិអំណាចមេបាលើកូនមានសិទ្ធិ និងចូលជួបប្រាស្រ័យទាក់ទងតាមវិធីដូចខាងក្រោម:

- ចូលជួបកូនបាន២(ពីរ) ដងក្នុងមួយខែ ដោយម្ដងៗមិនឲ្យលើសពី ២(ពីរ) ម៉ោង លើកលែងតែមានការអនុញ្ញាតពិសេស ពីអ្នកមានសិទ្ធិអំណាចមេបា។

- ចូលជួបកូននៅលំនៅដ្ឋានរបស់អ្នកមានសិទ្ធិអំណាចមេបា លើកលែងតែមានការអនុញ្ញាតពិសេសពីអ្នកមានសិទ្ធិអំណាចមេបា។

៤. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគីចុងចម្លើយ ។



Scanned with CamScanner

សាលក្រមនេះបានបញ្ចប់ការទាញហេតុផលនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ ចំពោះមុខភាគីដើមចោទឈ្មោះ [redacted] មករា និងភាគីចុងចម្លើយឈ្មោះ [redacted] ស៊ីវឿន។

ភាគីដែលមិនសុខចិត្តមានសិទ្ធិប្តឹងឧទ្ធរណ៍នឹងសាលក្រមនេះតាមការកំណត់របស់ច្បាប់៕

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃព្រហស្បតិ៍ ៧រោចខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

កណ្តាលថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]